ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# អនុស្សរណៈអន្តរការិយាល័យ

**ជូនចំពោះ÷** **ចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង** កាលបរិច្ឆេទ៖ ថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០១៤

**តាមរយៈ÷** **លោក គង់ សុភី**
**ប្រធានផ្នែកគ្រប់គ្រងតុលាការ**

**ពី÷** **លោក** Lars OLSEN
**មន្ត្រីច្បាប់នៃផ្នែកគ្រប់គ្រងតុលាការ**

**ចម្លងជូន÷** **ភាគីទាំងអស់, មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង, លោក គាំ ច័ន្ទមុន្នី និង លោក** Charles ZAMA **អង្គភាពបកប្រែភាសា អ្នកស្រី** Seynabou DIOP **អង្គភាពប្រតិចារឹក**

**កម្មវត្ថុ÷** **ការកែតម្រូវប្រតិចារឹកអនុលោមតាមវិធាន ៩៧ (៤) នៃវិធានផ្ទៃក្នុង**

១. កាលពីពេលកន្លងមក អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងទៅភាគីទាំងអស់ថា "ដើម្បីធ្វើឱ្យភាគីមានលទ្ធភាពក្នុងការស្នើសុំការកែតម្រូវកាន់តែមានប្រសិទ្ធភាពនូវកំហុសជាក់ស្តែងក្នុងការបកប្រែ និងការធ្វើប្រតិចារឹក និងបន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយអង្គភាពបកប្រែភាសា និងអង្គភាពប្រតិចារឹករួចមកនោះ ផ្នែកគ្រប់គ្រងតុលាការ (CMS) បានបញ្ជូន កាលពីពេលថ្មីៗនេះនូវបែបបទនីតិវិធីប្រតិបត្តិ ដែលនឹងទុកលទ្ធភាពឱ្យអង្គភាពទាំងនោះធ្វើការកែតម្រូវប្រតិចារឹកដោយខ្លួនឯងផ្ទាល់។ បន្ទាប់មកទៀត ប្រតិចារឹកទាំងប៉ុន្មានដែលបានកែ

00978378

E304.1

តម្រូវរួចនឹងត្រូវផ្នែកគ្រប់គ្រងតុលាការដាក់ដោយផ្ទាល់ទៅក្នុងសំណុំរឿង ដោយពុំចាំបាច់ស្វែងរកអន្តរាគមន៍ពីសំណាក់អង្គជំនុំជម្រះសាលាដំបូងឡើយ”[1]។

២. បន្ទាប់ពីផ្នែកគ្រប់គ្រងតុលាការ (CMS) បានអនុវត្តន៍នីតិវិធីថ្មីមក ភាគីខ្លះបានចោទសួរថាតើការអនុវត្តនីតិវិធីថ្មីនេះមានលក្ខណៈស្របទៅនឹងវិធានជាធរមាន ដែលគ្រប់គ្រងទៅលើការកែតម្រូវឯកសារផ្សេងៗនៅក្នុងសំណុំរឿងទេ។ ហេតុដូច្នេះ ផ្នែកគ្រប់គ្រងតុលាការបានត្រួតពិនិត្យទៅលើនីតិវិធីនៃការកែតម្រូវប្រតិចារឹក ដោយពិចារណាទៅលើវិធាន ៩៧(៤) នៃវិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក (សេចក្តីណែនាំអនុវត្ត)។ យើងក៏បានពិភាក្សាជាមួយមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងដែរ។

៣. យោងតាមវិធាន ៩៧(៤) អង្គជំនុំជម្រះសាលាដំបូងអាចពិចារណាលើពាក្យសុំកែតម្រូវលើប្រតិចារឹក។ ដូច្នេះ ផ្នែកគ្រប់គ្រងតុលាការស្នើសុំការអនុម័តពីអង្គជំនុំជម្រះសាលាដំបូងដើម្បីអនុវត្តនីតិវិធីកែតម្រូវប្រតិចារឹកដែលមានរៀបរាប់លម្អិតដូចខាងក្រោមនេះ។

៤. ភាគីដែលអះអាងថា ប្រតិចារឹកមានកំហុស ត្រូវដាក់ពាក្យសុំផ្ទៀងផ្ទាត់ប្រតិចារឹក[2] តាមសារអេឡិចត្រូនិក (E-mail) មកអង្គភាពប្រតិចារឹក ដោយចម្លងជូនទៅអង្គភាពបកប្រែភាសា និងមន្ត្រីទទួលបន្ទុកសំណុំរឿង។ ពាក្យសុំនេះត្រូវបញ្ជាក់ពីលេខសំណុំរឿង លេខឯកសារ ERN លេខទំព័រ និងជួរអក្សរ។ ពាក្យសុំនេះក៏ត្រូវផ្តល់ការពន្យល់ឱ្យបានច្បាស់អំពីមូលហេតុក្នុងការធ្វើសំណើនេះដែរ។

៥. ប្រសិនបើកំហុសនោះជាកំហុសនៃការធ្វើប្រតិចារឹក ប្រតិចារឹកនឹងត្រូវកែតម្រូវ ដោយអនុលោមតាមមាត្រា ៣.១៧ នៃសេចក្តីណែនាំអនុវត្ត ហើយភាគីទាំងអស់នឹងត្រូវបានជូនដំណឹងអំពីការកែតម្រូវនេះ។

៦. ប្រសិនបើកំហុសនេះគឺជាកំហុសនៃការបកប្រែផ្ទាល់មាត់ អង្គភាពបកប្រែភាសានឹងត្រួតពិនិត្យផ្នែកដែលមានបញ្ហានោះទាំងបីភាសា ហើយប្រសិនបើចាំបាច់ នឹងធ្វើការកែតម្រូវចំណុចនោះនៅក្នុងឯកសារជាភាសាមួយ ឬពីរភាសា ដើម្បីធានានូវភាពស្របគ្នានៅក្នុង

[1] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា “សំណើ E195 របស់ នៀវ សំផន និងនីតិវិធីទៅថ្ងៃមុខដែលនឹងអនុវត្តចំពោះការកែតម្រូវប្រតិចារឹក” ឯកសារ E195/1 ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១២។ កថាខណ្ឌ ២។

[2] សូមមើលពាក្យសុំធ្វើការផ្ទៀងផ្ទាត់ប្រតិចារឹក ដែលភ្ជាប់មកជាមួយនឹងអនុស្សរណៈនេះ។

ចំណោមឯកសារជាភាសាទាំងបី។ អត្ថបទដែលត្រូវកែតម្រូវនឹងត្រូវដាក់ចូលក្នុងចន្លោះសញ្ញា (<) និង (>)។ ប្រតិចារឹកនឹងត្រូវកែតម្រូវដោយអនុលោមតាមមាត្រា ៣.១៧ នៃសេចក្តីណែនាំអនុវត្ត ហើយភាគីផ្សេងៗនឹងត្រូវបានជូនដំណឹងអំពីការកែតម្រូវនោះ។ ប្រតិចារឹកដើមដែលមិនត្រូវបានកែតម្រូវនឹងត្រូវរក្សាទុកបន្តនៅក្នុងសំណុំរឿង ដោយអនុលោមតាមមាត្រា ៣.១៧(*ស្ទួន*)។ ផ្នែកដែលត្រូវបានកែតម្រូវក្នុងទម្រង់ជាឯកសារ PTF នឹងត្រូវបញ្ជូនទៅភាគីផ្សេងៗ។

៧. បន្ទាប់ពីពិភាក្សាជាមួយមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង មានការស្នើឡើងថាត្រូវដាក់ជើងទំព័រ (footer) ដោយយោងទៅពាក្យសុំកែតម្រូវប្រតិចារឹកនៅក្នុងសំណុំរឿង នៅលើគ្រប់ទំព័រដែលប្រតិចារឹកត្រូវបានកែតម្រូវ ដើម្បីប្រាប់អ្នកអានថា ប្រតិចារឹកនេះត្រូវបានកែតម្រូវ។ ដោយសារតែសេចក្តីណែនាំអនុវត្តមិនផ្តល់ការអនុញ្ញាតមកផ្នែកគ្រប់គ្រងតុលាការឱ្យដាក់ជើងទំព័រនៅក្នុងប្រតិចារឹក ទាំងប្រតិចារឹកដែលត្រូវបានកែតម្រូវ និងមិនត្រូវបានកែតម្រូវ ការអនុវត្តធ្វើបែបនេះនឹងតម្រូវឱ្យមានការណែនាំជាផ្លូវការពីអង្គជំនុំជម្រះសាលាដំបូង។

៨. ផ្នែកគ្រប់គ្រងតុលាការបានផ្អាកជាបណ្តោះអាសន្នក្នុងការដាក់ប្រតិចារឹក ដែលត្រូវបានកែតម្រូវទៅក្នុងសំណុំរឿង ដោយរង់ចាំការអនុម័តទៅលើនីតិវិធីដែលបានស្នើឡើងនៅក្នុងអនុស្សរណៈនេះ និង/ឬ ការណែនាំបន្ថែមទៀតពីអង្គជំនុំជម្រះសាលាដំបូងលើបញ្ហានេះ។៚